អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
# OFFICE OF THE CO-INVESTIGATING JUDGES

## សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត
## ការស៊ើបសួរក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-ECCC-OCIJ
## និងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរធ្វើឡើងដោយសហព្រះរាជអាជ្ញា របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងឲ្យបើកការស៊ើបសួរពាក់ព័ន្ធការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងខៀវ សំផន នួន ជា អៀង សារី អៀង ធីរិទ្ធ និងកាំងហ្គេចអ៊ាវ (ឌុច) នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (សំណុំរឿង ០០២)។

ដូចដែលបានបញ្ជាក់ប្រាប់នាដើមឆ្នាំ សហចៅក្រមស៊ើបអង្កេតសូមធ្វើការថ្លែងបញ្ជាក់ម្តងទៀតអំពីគំរោងបញ្ចប់ការស៊ើបសួរសំរាប់សំណុំរឿង ០០២ នេះ នៅចុងឆ្នាំ២០០៩។

កិច្ចប្រជុំពេញអង្គលើកទី៦របស់ អ.វ.ត.ក បានអនុម័តវិសោធនកម្មវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលទាក់ទងទៅនឹងពេលវេលាកំណត់នៃការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អនុលោមតាមវិសោធនកម្មនៃវិធានផ្ទៃក្នុង ជនណាដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរយ៉ាងយូរ១៥ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងថាសហក្រមចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន។

អនុលោមតាមវិធាន ៥៦. ២ ត្រង់ចំនុច (ក)នៃវិធានផ្ទៃក្នុង[1] ដើម្បីជួយដល់សាធារណជនទាំងឡាយដែលមានបំណងដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោយបានមុនពេលវេលាកំណត់ និងដើម្បីជួយបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានសម្រេចសូមផ្តល់ជូនព័ត៌មានអំពីទំហំនៃអង្គហេតុដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការស៊ើបសួររបស់ខ្លួន។

ព័ត៌មាននេះមិនត្រូវបានចាត់ទុកថាជាសេចក្តីសម្រេចរបស់តុលាការលើវិសាលភាពនៃការស៊ើបសួរក្នុងសំណុំរឿង ០០២ ឡើយ។

ក្នុងករណីមានការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ វិសាលភាពពិតប្រាកដនៃការចោទប្រកាន់នឹងត្រូវកំណត់នៅក្នុងដីកាដំណោះស្រាយ។

❁❁❁

អនុលោមតាមវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ជនរងគ្រោះគឺជារូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលរងការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត ដែលកើតចេញមកពីអំពើនៃការប្រព្រឹត្តបទល្មើសណាមួយដែលស្ថិតក្នុងយុត្តាធិការនៃ អ.វ.ត.ក។ ការខូចខាតដែលបានទទួលត្រូវតែជាផលវិបាកដោយផ្ទាល់ពីបទល្មើស ដោយបានកើតមានពិតប្រាកដមក និងទល់ពេលបច្ចុប្បន្ន។

ប្រសិនបើជនរងគ្រោះចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ការទទួលរងនូវព្យសនកម្មរបស់ពួកគេត្រូវតែផ្ទាល់ខ្លួន និងដោយផ្ទាល់ដែលជាប់ទាក់ទងនឹងស្ថានភាពអង្គហេតុមួយ ឬ ច្រើនដែលបង្កើតបានជាមូលដ្ឋាននៃការស៊ើបសួរ ដែលកំពុងដំណើរការ។

[1] សហចៅក្រមអាចៈ

ក- តាមរយៈផ្នែកកិច្ចការសាធារណៈ ផ្តល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឲ្យសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬ ដើម្បីកែតម្រូវព័ត៌មានមិនពិត ឬ ព័ត៌មាននាំឲ្យមានការភ័ន្តច្រឡំ។

សហចៅក្រមស៊ើបអង្កេតគ្រាន់តែធ្វើការស៊ើបសួរលើទំហំអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ។

អង្គហេតុខាងក្រោមនេះបង្កើតបានជាផ្នែកមួយនៃការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២៖

**I- សហករណ៍ និងការដ្ឋាននានា**

សហករណ៍ និងការដ្ឋានខាងក្រោមនេះស្ថិតនៅក្រោមការស៊ើបសួរ (តាមខេត្ត)

- **ខេត្តបន្ទាយមានជ័យ**

*ទំនប់ត្រពាំងថ្ម* ស្ថិតក្នុងស្រុកភ្នំស្រុក

- **ខេត្តកំពង់ឆ្នាំង**

*ព្រលានយន្តហោះកំពង់ឆ្នាំង* នៅជិតឃុំក្រាំងលាវ ស្រុករលៀផ្អៀ

- **ខេត្តកំពង់ធំ**

*ការដ្ឋានស្ទឹងជីនិតទំនប់ ១មករា* ស្ថិតនៅស្ទឹងជីនិត ស្រុកបារាយ និងសន្ទុក

- **ខេត្តកំពត**

*ការដ្ឋានស្រែអំបិល* ស្ថិតក្នុងភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកកំពត

- **ខេត្តតាកែវ**

*សហករណ៍ត្រាំកក់* ដែលរួមមានសហករណ៍ជាច្រើនស្ថិតនៅក្នុងឃុំដូចតទៅ៖ គូស សំរោង ត្រពាំងធំត្បូង ត្រពាំងធំជើង ត្រាំកក់ ញ៉ែងញ៉ង ស្រែរណុង និងតាផែន

- **ភ្នំពេញ**

*មន្ទីរស-២៤* (ស្គាល់ថាជាព្រៃស) ស្ថិតនៅក្នុងភូមិតាឡី ស្រុកចេក និងបាគូក្នុងឃុំព្រៃស ស្រុកដង្កោ

**II- មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សនានា**

មន្ទីរសន្តិសុខ និងកន្លែងសម្លាប់ខាងក្រោមនេះស្ថិតនៅក្រោមការស៊ើបអង្កេត (តាមខេត្ត)

- **ខេត្តបាត់ដំបង**

*មន្ទីរសន្តិសុខវត្តគីរីរម្យ* ស្ថិតនៅលើភ្នំគីរីរម្យ ស្រុកបាណន់

- **ខេត្តកំពង់ឆ្នាំង**

*កន្លែងសម្លាប់ព្រៃត្រពាំងអំពិល* នៅជិតភូមិជុំទាវជ្រេងថ្មី ស្រុកសាមគ្គីមានជ័យ(ពីមុនជាផ្នែកមួយនៃស្រុកកំពង់ត្រឡាច)

*មន្ទីរសន្តិសុខព្រៃដំរីស្រុត* ស្ថិតក្នុងភូមិដំរីស្រុត ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ និងតំបន់ដែលពាក់ព័ន្ធ ដូចជា៖

- វត្តត្រពាំងម្ទេសព្រៃ និងកន្លែងសម្លាប់ព្រៃតាគុជ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ នាឆ្នាំ១៩៧៥
- ព្រៃទទឹង ភូមិដំរីស្រុត ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ នាឆ្នាំ១៩៧៥
- ភ្នំគ្រេច ស្ថិតក្នុងឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ នាឆ្នាំ១៩៧៥
- ព្រៃស្រែវ៉ាល់ ភូមិថ្មីខ្មែរ ក្នុងឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ និងវត្តត្បែងខ្ពស់ នាឆ្នាំ១៩៧៥
- វត្តច្រកស្តេច ក្នុងឃុំពាម ស្រុកសាមគ្គីមានជ័យ នាឆ្នាំ១៩៧៥

- **ខេត្តកំពង់ចាម**

*កន្លែងសម្លាប់ស្ទឹងតូច* ស្ថិតនៅក្នុងឃុំកក់ ស្រុកពញាក្រែក

- **ខេត្តកណ្តាល**

*មន្ទីរសន្តិសុខសង់* ស្ថិតក្នុងស្រុកកណ្តាលស្ទឹង

- **ខេត្តកំពង់សោម**

*មន្ទីរសន្តិសុខកោះខ្យង* ស្ថិតក្នុងភូមិកោះខ្យង ឃុំអូរជ្រៅ (ពីមុនជាស្រុកព្រៃនប់)

- **ខេត្តក្រចេះ**

*មន្ទីរសន្តិសុខគោកក្តួច* ស្ថិតក្នុងស្រុកសំបូរ និងតំបន់ដែលពាក់ព័ន្ធ *មន្ទីរសន្តិសុខប្រាស្រាល់*

- **ខេត្តតាកែវ**

*មន្ទីរសន្តិសុខក្រាំងតាចាន់* ស្ថិតក្នុងឃុំ គូស ស្រុកត្រាំកក់

- **ខេត្តមណ្ឌលគីរី**

*មន្ទីរសន្តិសុខភ្នំក្រោល* ស្ថិតនៅស្រុកកោះញែក ឃុំស្រែសង្គម ភូមិ ៩

- **ភ្នំពេញ**

*មន្ទីរស-២១* ស្ថិតនៅផ្លូវ ១០៣ សង្កាត់បឹងកេងកង ៣ ខ័ណ្ឌចំការមន និងទីកន្លែងពាក់ព័ន្ធដូចជា ទីកន្លែងសម្លាប់មនុស្សនៅជើងឯក

- **ខេត្តពោធិ៍សាត់**

*កន្លែងសម្លាប់ទួលពោធិជ្រៃ* ស្ថិតនៅព្រីងខ្ពស់ ស្រុកកណ្ដៀង

- **ខេត្តរតនគីរី**

*មន្ទីរសន្តិសុខ អូរកន្សែង/ភូមិ ៣* ជាទូទៅស្ថិតនៅឃុំឡាបានសៀក ស្រុកបានលុង

- **ខេត្តសៀមរាប**

*មន្ទីរសន្តិសុខសៀមរាប* ពីដើមស្ថិតនៅទល់មុខសាលាដំបូង។ វារួមទាំងវត្ត ដាម៉ាយុទ្ធី (ហៅ វត្តធម្មយុទ្ធ ឬវត្តកេសារារាម)

- **ខេត្តស្វាយរៀង**

*មន្ទីរសន្តិសុខវត្តផ្លក* ស្ថិតក្នុងភូមិផ្លក ស្រុកស្វាយជ្រុំ (ហៅស្រុកមានជ័យថ្មីក្នុងកំលុងរបបកម្ពុជាប្រជាធិបតេយ្យ)

## III- អំពើប្រព្រឹត្តប្រឆាំងនឹងប្រជាជន និង/ឬ ក្រុមមនុស្សមួយចំនួន

- *ការផ្លាស់កន្លែងប្រជាជន*ភ្លាមៗចេញពីភ្នំពេញបន្ទាប់ពីថ្ងៃទី ១៧ មេសា ១៩៧៥
- *ការផ្លាស់កន្លែងប្រជាជន*ពីភូមិភាគកណ្ដាល និងភូមិភាគនីរតីនៃប្រទេស ទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ (ខេត្តបាត់ដំបង និង/ឬពោធិសាត់) នៅចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦ ជាពិសេសទាក់ទងនឹងប្រព្រឹត្តកម្មលើជនជាតិភាគតិចចាម។
- *ការផ្លាស់កន្លែងប្រជាជន*ពីភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ ជាពិសេសពីព្រៃវែង និង ស្វាយរៀង ទៅខេត្តពោធិសាត់ និងបាត់ដំបង។

- *ប្រព្រឹត្តកម្មលើពុទ្ធសាសនិក*នៅក្នុងប្រទេសកម្ពុជាជាពិសេស

  *វត្តចំបក់* ស្ថិតនៅភូមិទួលស្ដី ឃុំទួលស្ដី ស្រុកចន្ទ្រា ខេត្តស្វាយរៀង

  *វត្តតាគុត និងវត្តម៉ែ* ស្ថិតនៅក្នុងភូមិដៃតូច ឃុំដៃធំ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល

  *វត្តអន្ទង់រៀន* ហៅវត្តមុនីវង្សអន្ទង់រៀន ស្ថិតក្នុងភូមិអន្ទង់រៀន ឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ

  *វត្តដំណាក់ត្រយឹង* ស្រុកទូកមាស ខេត្តកំពត

  *វត្តជ័យមង្គល* ស្ថិតនៅក្នុងភូមិកំភុន ឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង

  *វត្តសំរោង* ស្ថិតក្នុងភូមិសំរោង ឃុំសំរោង ស្រុកឯកភ្នំ ខេត្តបាត់ដំបង

- *ប្រព្រឹត្តកម្មលើជនជាតិវៀតណាម*នៅក្នុងខេត្តព្រៃវែងនិងខេត្តស្វាយរៀងនិងកំលុងពេលវាយប្រយុទ្ធទៅលើ

វៀតណាម

- *ប្រព្រឹត្តកម្មលើជនជាតិភាគតិចចាម* នៅក្នុងភូមភាគកណ្តាល បូព៌ា និងពាយ័ព្យនិងជាពិសេសនៅក្នុងខេត្ត កំពង់ចាម៖
    - o *ភូមិទ្រា II* ដែលស្ថិតនៅក្នុងស្រុកក្រូចឆ្មារ
    - o *វត្តអូរត្រកួន* ដែលស្ថិតនៅក្នុងស្រុកកងមាស
- *ការបោសសំអាតខ្មាំង*ផ្ទៃឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេសនៅភូមិភាគឧត្តរ (ចាស់ និង/ឬថ្មី) នាឆ្នាំ១៩៧៦ ហើយនិងនៅភូមិភាគឧត្តរ (ថ្មី) នាចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ ១៩៧៧ និងនៅក្នុង ភូមិភាគបូព៌ា ក្នុងឆ្នាំ ១៩៧៨។
- *ការរៀបការដោយបង្ខំ* ដែលកើតមានឡើងនៅរបបកម្ពុជាប្រជាធិបតេយ្យ

❀❀❀

ជនណាដែលគិតថាខ្លួនស្ថិតក្នុងនិយមន័យនៃដើមបណ្តឹងរដ្ឋប្បវេណីចែងក្នុងវិធាន២៣.២ នៃវិធានផ្ទៃក្នុង និងមាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្តស្តីការចូលរួមរបស់ជនរងគ្រោះ ដោយមានជាប់ពាក់ព័ន្ធបទឧក្រិដ្ឋកម្មដែលបានលើក ឡើងខាងលើ និង ជនណាដែលមានបំណងដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងដំណើរការ កាត់សេចក្តីរបស់ អ.វ.ត.ក អាចទាក់ទងមកអង្គភាពជនរងគ្រោះរបស់ អ.វ.ត.ក ភ្លាមៗតាមដែលអាចធ្វើទៅបាន តាមអស័យដ្ឋានដូចតទៅ៖

អង្គភាពជនរងគ្រោះ
ផ្ទះលេខ ៦A ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់ ១ ខ័ណ្ឌចំការមន ភ្នំពេញ ប្រទេសកម្ពុជា
លេខទូរស័ព្ទ ០១២ ៨៤២៨៦១ ឬ ០៩៧ ៧៤២៤២១៨ ឬ ០២៣ ២១៤ ២៩១

អង្គភាពជនរងគ្រោះត្រៀមខ្លួនជាស្រេចដើម្បីជួយ និងផ្តល់ការពន្យល់នានាថែមទៀតសំរាប់ ជនទាំងឡាយណាមាន បំណងបំពេញទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ។ ការិយាល័យអង្គភាពជនរងគ្រោះបើកបំរើការចាប់ពីម៉ោង ៨:០០ ពេលព្រឹក ដល់ម៉ោង ៥:០០ ពេលល្ងាច ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សំរាកផ្លូវការ។

❀❀❀

សូមមើល

ទំនាក់ទំនងផ្ញើសារទៅអង្គភាពជនរងគ្រោះសំរាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

http://www.eccc.gov.kh/khmer/cabinet/press/102/vu_statement_kh.pdf